# ពុទ្ធវចនៈ




*ក្នុងព្រះពុទ្ធសាសនាមានគម្ពីរសំខាន់ ៣ ប្រភេទ គឺ*

*១. ព្រះត្រៃបិដក*

*២. អដ្ឋកថា*

*៣. ដីកា*

## ១. ព្រះត្រៃបិដក

*ព្រះត្រៃបិដកជាគម្ពីរដែលតម្កល់ពុទ្ធវចនៈ  គឺពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ហៅថា នវង្គសត្ថុសាសន៍ បានដល់ ពាក្យប្រៀបប្រដៅរបស់ ព្រះសាស្ដាមានអង្គ ៩ គឺ*

*១. **សុត្ត:** បានដល់ ឧភតោវិភង្គ និទ្ទេស បរិវារៈ ព្រះសូត្រក្នុង សុត្តនិបាត និងពុទ្ធវចនៈដទៃៗ ដែលមានឈ្មោះថា សុត្តៈ ឬ សុត្តន្តៈ ដោយសរុប គឺវិន័យបដិក គម្ពីរនិទ្ទេស និង ព្រះសូត្រទាំង ។*

*២. **គេយ្យ:** បានដល់ កម្រងកែវ និងកម្រងរងលាយគ្នា សំដៅយក ព្រះសូត្រដែលមានគាថាទាំងអស់ ដោយចំពោះសភាថវគ្គក្នុង សំយុត្តនិកាយ ។*

*៣. **វេយ្យាករណៈ** បានដល់ កម្រងកែវសុទ្ធ សំដៅយកព្រះអភិធម្ម-បដិកទាំងអស់ ព្រះសូត្រមិនមានគាថា និងពុទ្ធវចនៈដទៃមិនចាត់ចូល ក្នុងអង្គ ៨ ។*

*៤. **គាថា** បានដល់ កម្រងរងសុទ្ធ សំដៅយកធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធក្នុងសុត្តនិបាតដែលមិនមានឈ្មោះថា ជាសូត្រ ។*

*៥. **ឧទាន** បានដល់ គាថា (អត្ថបទជាកម្រងរង) ដែលទ្រង់បន្លឺចេញ មកដោយព្រះទ័យ សោមនស្សសម្បយុត្តដោយញាណ (ជាប្រភេទកម្រង កែវក៏មាន មើលខុទ្ទកនិកាយ ឧទាន) រួមជា ៨២ សូត្រ ។*

*៦. **ឥតិវុត្តកៈ** បានដល់ ព្រះសូត្រ ១១០ ដែលផ្ដើមដោយន័យថា វុត្តំ ហេតំ ភគវតា សម ដូចព្រះមានព្រះភាគត្រាស់ទុក មើលខុទ្ទកនិកាយ ឥតិវុត្តកៈ ។*

*៧. **ជាតក** បានដល់ ជាតក ៥៥០ រឿង មានអបណ្ណកជាតកជាដើម រហូតដល់ វេស្សន្តរជាតកជាទីបំផុត តែក្នុងព្រះត្រៃបិដកមានចំនួន ៥៤៧ ជាតកប៉ុណ្ណោះ ។*

*៨. **អព្ភូតធម្មៈ** បានដល់ ព្រះសូត្រដែលពោលដល់ហេតុអស្ចារ្យ សំដៅយកព្រះសូត្រដែលពោលដល់អច្ឆរិយៈមិនធ្លាប់ដែលមាន ដូច ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យមិនធ្លាប់មាន ៤ យ៉ាងនេះ មានដល់អានន្ទ ជាដើម ។*

*៩. **វេទល្លៈ** បានដល់ ព្រះសូត្របែបសួរឆ្លើយ ដែលអ្នកសួរបាន ក៏បានដឹង (វេទ) និង សេចក្ដីពេញចិត្ត (តុដ្ឋិ) សួររឿយៗ ដូចចូឡវេទល្ល-សូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារសូត្រ និង មហាបុណ្ណមសូត្រ ។*

*នវង្គសត្ថុសាសន៍នេះ ពោលតាមន័យ អដ្ឋកថា វិន័យបិកដ មហាវិភង្គ ។*

## ចំនួនព្រះត្រៃបិដក

*ព្រះត្រៃបិដកទាំង ៣ គឺ វិន័យបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ រាប់ជាធម្មក្ខន្ធមានចំនួន ៨៤០០០ ធម្មក្ខន្ធ គឺ វិន័យបិដក ២១០០០ ធម្មក្ខន្ធ, សុត្តន្តបិដក ២១០០០ ធម្មក្ខន្ធ, អភិធម្មបិដក ៤២០០០ ធម្មក្ខន្ធ រាប់ជាចំនួនសៀវភៅមានចំនួន ១១០ ភាគ ។*

## ព្រះត្រៃបិដកខ្មែរ

### *ព្រះត្រៃបិដក ជាភាសាបាលី និង ភាសាសម្រាយ*

### ១. វិនយបិដក

*១. មហាវិភង្គ បឋមភាគ ១ វេរញ្ជកណ្ឌ និង បារាជិកកណ្ឌ*

*២. មហាវិភង្គ ទុតិយភាគ ២ តេរសកណ្ឌ និង អនិយតកណ្ឌ*

*៣. មហាវិភង្គ តតិយភាគ ៣ និស្សគ្គិយកណ្ឌ និង បាចិត្តិយកណ្ឌ*

*៤. មហាវិភង្គ ចតុត្ថភាគ ៤ បាចិត្តិយកណ្ឌ បាដិទេសនីយកណ្ឌ សេក្ខិយ-កណ្ឌ អធិករណសមថកណ្ឌ*

*៥. ភិក្ខុនីវិភង្គ បច្ឆិមភាគ ៥*

*៦. មហាវគ្គ បឋមភាគ ៦ មហាខន្ធកៈ ឧបោសថក្ខន្ធកៈ*

*៧. មហាវគ្គ ទុតិយភាគ ៧ វស្សូបនាយិកក្ខន្ធកៈ វស្សូបនាយិកក្ខន្ធកៈ បវារណាក្ខន្ធកៈ ចម្មក្ខន្ធកៈ និង ភេសជ្ជក្ខន្ធកៈ*

*៨. មហាវគ្គ តតិយភាគ ៨ កឋិនក្ខន្ធកៈ ចីវរក្ខន្ធកៈ ចម្បេយ្យក្ខន្ធកៈ និង កោសម្ពិក្ខន្ធកៈ*

*៩. ចុល្លវគ្គ បឋមភាគ ៩ កម្មក្ខន្ធកៈ បារិវាសិកក្ខន្ធកៈ និង សមុច្ចយក្ខន្ធកៈ*

*១០. ចុល្លវគ្គ ទុតិយភាគ ១០ សមថក្ខន្ធកៈ ខុទ្ទកវត្ថុក្ខន្ធកៈ និង សេនាសនក្ខន្ធកៈ*

*១១. ចុល្លវគ្គ តតិយភាគ ១១ សង្ឃភេទក្ខន្ធកៈ វត្តក្ខន្ធកៈ បាតិមោក្ខដ្ឋបន-ក្ខន្ធកៈ ភិក្ខុនិក្ខន្ធកៈ បញ្ចសតិកក្ខន្ធកៈ និង សត្តសតិកក្ខន្ធកៈ*

*១២. បរិវារ បឋមភាគ ១២ មហាវិភង្គ សោឡសមហាវារៈ ភិក្ខុនីវិភង្គ សោឡសមហាវារៈ សមុដ្ឋានសីសសង្ខេប កតិបុច្ឆាវារៈ និង វីសតិវារៈ*

១៣. បរិវារ ទុតិយភាគ ១៣ ខន្ធកបុច្ឆា ឯកុត្តរិកៈ ឧបោសថាទិបុច្ឆា-វិស្សជ្ជនា អត្ថវសេបករណៈ គាថាសង្គណិកៈ និង អធិករណភេទជាដើម

**២. សុត្តន្តបិដក**

១៤. ទីឃនិកាយ បឋមភាគ សីលក្ខន្ធវគ្គ ១៤

១៥. ទីឃនិកាយ ទុតិយភាគ សីលក្ខន្ធវគ្គ ១៥

១៦. ទីឃនិកាយ តតិយភាគ មហាវគ្គ ១៦

១៧. ទីឃនិកាយ ចតុត្ថភាគ មហាវគ្គ ១៧

១៨. ទីឃនិកាយ បញ្ចមភាគ បាដិកភាគ ១៨

១៩. ទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ ១៩

២០. មជ្ឈិមនិកាយ មូលបណ្ណាសកៈ បឋមភាគ ២០

២១. មជ្ឈិមនិកាយ មូលបណ្ណាសកៈ ទុតិយភាគ ២១

២២. មជ្ឈិមនិកាយ មូលបណ្ណាសកៈ មហាយមកៈវគ្គ ២២

២៣. មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ ចតុត្ថភាគ ២៣

២៤. មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ បញ្ចមភាគ ២៤

២៥. មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ ឆដ្ឋភាគ ២៥

២៦. មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ សត្តមភាគ ២៦

២៧. មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ឆដ្ឋភាគ ២៧

២៨. មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ នវមភាគ ២៨

២៩. សំយុត្តនិកាយ សគាថាវគ្គ បឋមភាគ ២៩

៣០. សំយុត្តនិកាយ សគាថាវគ្គ ទុតិយភាគ ៣០

៣១. សំយុត្តនិកាយ និទានវគ្គ តតិយភាគ ៣១

៣២. សំយុត្តនិកាយ និទានវគ្គ ចតុត្ថភាគ ៣២

៣៣. សំយុត្តនិកាយ ខន្ធវារវគ្គ បញ្ចមភាគ ៣៣

៣៤. សំយុត្តនិកាយ ខន្ធវារវគ្គ ឆដ្ឋភាគ ៣៤

៣៥. សំយុត្តនិកាយ សឡាយតនវគ្គ សត្តមភាគ ៣៥
៣៦. សំយុត្តនិកាយ សឡាយតនវគ្គ អដ្ឋមភាគ ៣៦
៣៧. សំយុត្តនិកាយ មហាវារវគ្គ នវមភាគ ៣៧
៣៨. សំយុត្តនិកាយ មហាវារវគ្គ សទមភាគ ៣៨
៣៩. សំយុត្តនិកាយ មហាវារវគ្គ ឯកាសទមភាគ ៣៩
៤០. អង្គុត្តរនិកាយ ឯកក-ទុកនិបាត បឋមភាគ ៤០
៤១. អង្គុត្តរនិកាយ តិកនិបាត ទុតិយភាគ ៤១
៤២. អង្គុត្តរនិកាយ ចតុក្កនិបាត តតិយភាគ ៤២
៤៣. អង្គុត្តរនិកាយ ចតុក្កនិបាត ចតុត្ថភាគ ៤៣
៤៤. អង្គុត្តរនិកាយ បញ្ចកនិបាត បញ្ចមភាគ ៤៤
៤៥. អង្គុត្តរនិកាយ បញ្ចកនិបាត ឆដ្ឋភាគ ៤៥
៤៦. អង្គុត្តរនិកាយ ឆក្កនិបាត សត្តមភាគ ៤៦
៤៧. អង្គុត្តរនិកាយ សត្តកនិបាត អដ្ឋភាគ ៤៧
៤៨. អង្គុត្តរនិកាយ អដ្ឋកនិបាត នវមភាគ ៤៨
៤៩. អង្គុត្តរនិកាយ នវកនិបាត ទសមភាគ ៤៩
៥០. អង្គុត្តរនិកាយ ទសកនិបាត ឯកាទសមភាគ ៥០
៥១. អង្គុត្តរនិកាយ ទសកនិបាត ឯកាទសកនិបាត ទ្វាទសមភាគ ៥១
៥២. ខុទ្ទកនិកាយ ខុទ្ទកបាឋ, ធម្មបទគាថា, ឧទាន, ភាគ ៥២
៥៣. ខុទ្ទកនិកាយ ឥតិវុត្តកៈ ទុតិយភាគ ៥៣
៥៤. ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ ៥៤
៥៥. ខុទ្ទកនិកាយ វិមានវត្ថុ ចតុត្ថភាគ ៥៥
៥៦. ខុទ្ទកនិកាយ បេតវត្ថុ ថេរគាថា បញ្ចមភាគ ៥៦
៥៧. ខុទ្ទកនិកាយ ថេរគាថា ថេរីគាថា ឆដ្ឋភាគ ៥៧

៥៨. ខុទ្ទកនិកាយ ជាតក សត្តមភាគ ៥៨

៥៩. ខុទ្ទកនិកាយ ជាតក អដ្ឋមភាគ ៥៩

៦០. ខុទ្ទកនិកាយ ជាតក នវមភាគ ៦០

៦១. ខុទ្ទកនិកាយ ជាតក ទសមភាគ ៦១

៦២. ខុទ្ទកនិកាយ ជាតក ឯកាទសមភាគ ៦២

៦៣. ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ ៦៣

៦៤. ខុទ្ទកនិកាយ មហានិទ្ទេស បឋមភាគ ៦៤

៦៥. ខុទ្ទកនិកាយ មហានិទ្ទេស ទុតិយភាគ ៦៥

៦៦. ខុទ្ទកនិកាយ មហានិទ្ទេស តតិយភាគ ៦៦

៦៧. ខុទ្ទកនិកាយ ចូឡនិទ្ទេស បឋមភាគ ៦៧

៦៨. ខុទ្ទកនិកាយ ចូឡនិទ្ទេស ទុតិយភាគ ៦៨

៦៩. ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ បឋមភាគ ៦៩

៧០. ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ទុតិយភាគ ៧០

៧១. ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ តតិយភាគ ៧១

៧២. ខុទ្ទកនិកាយ អបទាន បឋមភាគ ៧២

៧៣. ខុទ្ទកនិកាយ អបទាន ទុតិយភាគ ៧៣

៧៤. ខុទ្ទកនិកាយ អបទាន តតិយភាគ ៧៤

៧៥. ខុទ្ទកនិកាយ អបទាន ចតុត្ថភាគ ៧៥

៧៦. ខុទ្ទកនិកាយ អបទាន បញ្ចមភាគ ៧៦

៧៧. ខុទ្ទកនិកាយ ពុទ្ធវំសៈ ចរិយាបិដក ៧៧

**៣. អភិធម្មបិដក**

៧៨. ធម្មសង្គណិ បឋមភាគ ៧៨

៧៩. ធម្មសង្គណិ ទុតិយភាគ ៧៩

៨០. វិភង្គ បឋមភាគ ៨០

៨១. វិភង្គ ទុតិយភាគ ៨១

៨២. វិភង្គ តតិយភាគ ៨២

៨៣. ធាតុកថា បុគ្គលប្បញ្ញត្តិ ៨៣

៨៤. កថាវត្ថុ បឋមភាគ ៨៤

៨៥. កថាវត្ថុ ទុតិយភាគ ៨៥

៨៦. កថាវត្ថុ តតិយភាគ ៨៦

៨៧. យមកៈ បឋមភាគ ៨៧

៨៨. យមកៈ ទុតិយភាគ ៨៨

៨៩. យមកៈ តតិយភាគ ៨៩

៩០. យមកៈ ចតុត្ថភាគ ៩០

៩១. យមកៈ បញ្ចមភាគ ៩១

៩២. យមកៈ ឆដ្ឋភាគ ៩២

៩៣. យមកៈ សត្តមភាគ ៩៣ (មាន៨ក្បាល)

៩៤. បដ្ឋាន បឋមភាគ ៩៤

៩៥. បដ្ឋាន ទុតិយភាគ ៩៥

៩៦. បដ្ឋាន តតិយភាគ ៩៦

៩៧. បដ្ឋាន ចតុត្ថភាគ ៩៧

៩៨. បដ្ឋាន បញ្ចមភាគ ៩៨

៩៩. បដ្ឋាន ឆដ្ឋភាគ ៩៩

១០០. បដ្ឋាន សត្តមភាគ ១០០

១០១. បដ្ឋាន អដ្ឋមភាគ ១០១

១០២. បដ្ឋាន នវមភាគ ១០២

១០៣. បដ្ឋាន ទសមភាគ ១០៣

១០៤. បដ្ឋាន ឯកាទសមភាគ ១០៤

១០៥. បដ្ឋាន ទ្វាទសមភាគ ១០៥

១០៦. បដ្ឋាន តេរសមភាគ ១០៦

១០៧. បដ្ឋាន ចុទ្ទសមភាគ ១០៧

១០៨. បដ្ឋាន បណ្ណរសមភាគ ១០៨

១០៩. បដ្ឋាន សោឡសមភាគ ១០៩

១១០. បដ្ឋាន សត្តរសមភាគ ១១០ ។ (មាន១៧ក្បាល)

នៅក្នុងព្រះត្រៃបិដកខ្មែរមិនមានឈ្មោះព្រះសូត្រគ្រប់ទាំងអស់នោះ ទេ គឺមានឈ្មោះព្រះសូត្រតែក្នុងទីឃនិកាយទាំងអស់, មជ្ឈិមនិកាយ ទាំងអស់, សំយុត្តនិកាយ សគាថវគ្គ, ខុទ្ទកនិកាយ ខុទ្ទកបាឋៈ និង ខុទ្ទកនិកាយ សុត្តនិបាតតែប៉ុណ្ណោះ ក្រៅពីនេះគឺ សំយុត្តនិកាយ និទានវគ្គ, ខន្ធវគ្គ, សឡាយតនវគ្គ, មហាវគ្គ, អង្គុត្តរនិកាយ, ខុទ្ទកនិកាយ ឧទាន, ឥតិវុត្តកៈ មិនមានឈ្មោះ ឲ្យដឹងព្រះសូត្រហ្នឹងឈ្មោះអីឡើយ គឺមានឈ្មោះ វគ្គប៉ុណ្ណោះ ដូច្នេះហើយបានខ្ញុំព្រះករុណាខ្ញុំបាទ បានដកស្រង់ឈ្មោះ ព្រះសូត្រទាំងអស់ពីព្រះត្រៃបិដកឆដ្ឋសង្គាយនា យកមកដាក់និងប្រាប់ លេខបិដក និងលេខទំព័រ ឲ្យត្រូវនឹងព្រះត្រៃបិដកខ្មែរ ដើម្បីងាយស្រួល ដល់សិក្សាស្រាវជ្រាវ ហើយឈ្មោះសូត្រទាំងអស់នេះ មានឈ្មោះខ្វះមិនដូចឈ្មោះក្នុងព្រះត្រៃបិដកខ្មែរទេ តែក៏គឺព្រះសូត្រហ្នឹងឯង គ្រាន់តែមាន ឈ្មោះខុសគ្នាខ្វះតិចតួចប៉ុណ្ណោះ ។

(សុត្តានុក្រម វគ្គានុក្រម គាថានុក្រម ជាតកានុក្រម អបទានានុក្រម ពុទ្ធវំសានុក្រម និង ចរិយានុក្រម)

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
ដោយស.ដ.វ.ថ.
ព.ស. ២៥៥៨